សារព័ត៌មាន ខ្មែរផុស ស.រ.អា
Free
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US

MAYURA
Video . Fashion Jewelry . Hair Clips
978 998 0707 | 978 4558766
ផ្ញើរអីវ៉ាន់ទៅវិញទៅមកស្រុកខ្មែរ
ផ្ញើរតាមយន្តហោះ 1ផោន $11
ផ្ញើរតាមកប៉ាល់ 1ផោន $4
ធានាសងលុយវិញ បើសិនបាត់

21 branch St. Lowell, MA 01851
Visit us on Facebook : MayuraLowell

## ព័ត៌មានសំខាន់ៗខាងក្នុង...

### មនុស្សចាស់ខ្មែរនៅរដ្ឋម៉ាសាឈូសេត

សូមអាននៅទំព័រទី ០២



### សម្ម រង្ស៊ី ទទួលការគាំទ្រពីគណៈចិនន្រ្តើយ៍

សូមអាននៅទំព័រទី ០៩



### រនាំងអន្តោប្រវេសន៍មិនបានសង់ តើត្រូវបន្ទោស..

សូមអាននៅទំព័រទី ១០



# “ខ្ញុំស្រម័យឃើញ...”របស់ ម៉ាទីន លូធើរ ឃីង




ដោយ ពិន សំខុន

លោកប៉ាស្ទ័រ ម៉ាទីន លូធ័រ ឃីង បានត្រូវប្រជាពលរដ្ឋអាមេរិកាំងចងចាំសកម្មភាពរបស់លោករហូតមកទល់ថ្ងៃនេះ ដោយសារការតស៊ូបំរើមនុស្សជាតិរបស់លោក ដើម្បីលុបបំបាត់ការរើងអើងប្រកាន់ពូជសាសន៍ ។លោកបានធ្វើសុន្ទរកថាដ៏ល្បីល្បាញមួយប្រកបដោយអត្ថន័យផ្អែមល្ហែមនៅវ៉ាស៊ីនតោនឌីស៊ី បង្ហាញពីការចង់ឃើញការស្រឡាញ់មនុស្សជាតិដូចគ្នា ដោយមិនប្រកាន់ពណ៌សម្បុរឱ្យដូចជាបងប្អូនបង្កើត“ខ្ញុំស្រម័យឃើញ- I have a Dream”... លោកបានដើរផ្សព្វផ្សាយធម៌ “សទ្ធិពលរដ្ឋ”នេះ ពីដំបន់មួយទៅដំបន់មួយទៀត រហូតដល់មានមនុស្សលួចសម្លាប់លោកនាថ្ងៃទី៤មេសា ឆ្នាំ១៩៦៨ នៅរដ្ឋថេនីស៊ី ។

ខុសពីបំណងឃាដករ ទោះជាលោក ឃីង ស្លាប់ទៅហើយក្តី ការតស៊ូរបស់លោកមិនបានត្រូវបញ្ចប់នោះទេ ក្រុមឃាដកររបែរជាបានធ្វើឱ្យ “កម្លាំងតស៊ូដើម្បីសិទ្ធិមនុស្ស”បន្តបន្ទាប់គុណជាទ្វេដង បណ្តាលឱ្យមានសេចក្តីសម្រេចនៅសភាអាមេរិកាំងផ្តល់សិទ្ធបោះឆ្នោតឱ្យបណ្តាពួកស្បែកខ្មៅ ឱ្យអាចឈរឈ្មោះជាមន្ត្រីគ្រប់ជាន់ថ្នាក់បានរហូតដល់ចុងក្រោយបង្អស់ មានជនស្បែកខ្មៅបានឡើងកាន់ខ្ពង់ខ្ពស់បំផុត ជាប្រធានាធិបតីស្បែក

តទៅទំព័រទី ០៤

I DO TAXES

Law Office of Thomas Stylianos
978-459-5000
មានបទពិសោធន៍២៥ឆ្នាំ
យើងបម្រើធ្វើតាក់សម្រាប់លោកអ្នក
ការិយាល័យយើងខ្ញុំ បើកទាំងពេលយប់ និងចុងសប្តាហ៍ (រដូវធ្វើតាក់)
287 Appleton Street. Lowell MA 01852

មេធាវី លុយហាស្គែល
Law Office of Louis S. Haskell
Serving the Cambodian Community since 1987
PERSONAL INJURY របួសរាងកាយ
AUTO ACCIDENTS គ្រោះថ្នាក់ចរាចរ


978-459-8359
16 Pine Street - Lowell, MA | www.attorneyhaskell.com


ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
• Immigration •អន្តោប្រវេសន៍
• Auto Crash •គ្រោះថ្នាក់រថយន្ត
• Divorce •លែងលះប្តីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com

# មនុស្សចាស់ខ្មែរនៅរដ្ឋម៉ាសាឈូសិត

ដោយ សូបិន ពិន

"មនុស្សចាស់"បច្ចុប្បន្នកំពុងតែក្លាយជាវិបត្តិបញ្ហាចំបងរបស់សង្គមអាមេរិកាំងហើយ បើតាមលទ្ធផលនៃការជំរឿនប្រជាជននៅឆ្នាំ២០២០ នឹងមានមនុស្សចាស់ចូលនិវត្តន៏អាយុ៦៥ឆ្នាំ នៅមានជីវិតក្នុងចំនួនកាន់តែច្រើន មិនដូចការប៉ានស្មានពីមុនមកនោះទេ, ហើយអ្នកដែលចិញ្ចឹម មើលថែទាំទុកដាក់លើ"មនុស្សចាស់"ទាំងនោះ គឺជាក្មេងជំនាន់ក្រោយ ចំនួនកាន់តែតិច ខិតខំធ្វើការរកប្រាក់មកចិញ្ចឹមពួកគាត់។ បុព្វហេតុ គឺអ្នកដែលកើតចន្លោះ១៩៤៦-១៩៦៤ បានកើនចំនួនយ៉ាងខ្លាំង "ទារកផ្ទុះឡើង Beby Boomer"មកពីបច្ចេកវិទ្យានឹងវិជ្ជាពេទ្យ បានពន្យាជីវិតមនុស្សឱ្យកាន់តែវែងទៅៗ ហើយដល់ឆ្នាំ២០៣០ នឹងមានមនុស្សវ័យចាស់ឈានចូលអាយុ៦៥ចំនួន១០.០០០នាក់ក្នុងមួយថ្ងៃ ដែលចំនួននោះបានឡើងដល់២០% នៃពលរដ្ឋទាំងអស់ទៅហើយ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៤ មនុស្សចាស់នោះ មានតែ១៤,៥%តែប៉ុណ្ណោះ ដូច្នេះចំនួនថវិការដែលត្រូវការយកមកផ្គត់ផ្គង់ដល់"មនុស្សចាស់"ក៏កាន់តែមានចំនួនច្រើន។

នៅរដ្ឋម៉ាសាឈូសិតនេះ បើយោងតាមស្ថិតិសហគមន៏អាមេរិកាំង មានផ្ទះគ្រួសារខ្មែរចំនួន ១,៣៣២ ដែលក្នុងនោះមានមនុស្សចាស់អាយុច្រើនជាង៦៥ឆ្នាំ យ៉ាងហោចណាស់ក៏ម្នាក់ឬក៏ច្រើនជាងម្នាក់ដែរ...។



ប្រជាជនខ្មែរក៏ជាសហគមន៏ដ៏ធំមួយដែរ មានមនុស្សចាស់ក៏ច្រើន នឹងក្លាយជាបញ្ហាដូចគ្នានឹងពលរដ្ឋអាមេរិកាំងឯទៀតជាមិនខាន-៩០%នៃមនុស្សចាស់ខ្មែរអាយុលើសពី៦៥ឆ្នាំតែងមានជម្ងឺប្រចាំកាយ ដូចជាជម្ងឺទឹកនោមផ្អែម, ជម្ងឺបេះដូង, ជម្ងឺរំជួលចិត្ត, ឈឺសន្លាក់ដៃជើង, ជម្ងឺលើសឈាម។ រឹតតែច្រើនទៅទៀត មនុស្សចាស់ទាំងនោះ មានជម្ងឺផ្លូវចិត្តបណ្តាលមកពីការលំបាកពីអតីតកាលដោយសល់ពីស្លាប់ក្នុសសង្គ្រាមនៅកម្ពុជា នាចន្លោះឆ្នាំ១៩៧៥-៧៩%ជំនាន់ខ្មែរក្រហមកាន់កាប់)ពេលនោះមានមនុស្សជាង២លាននាក់បានត្រូវគេ សម្លាប់ ឬក៏បានអត់ម្ហូបអាហារបរិភោគ នឹងដោយជម្ងឺនានា។

បានគេចរួចពីកម្ពុជាមកដល់សហរដ្ឋអាមេរិកនាឆ្នាំ១៩៨០ ខ្មែរជំទង់ៗទូទៅ មានក៏រីតអប់រំសិក្សាត្រឹមតែថ្នាក់ទី៤តែប៉ុណ្ណោះ អ្នកទាំងនោះមានឧបសគ្គផ្នែកភាសានឹងវប្បធមិស្មើរគ្រប់គ្នា ហើយនាពេលនេះក្លាយជាមនុស្សចាស់ៗរបស់ប្រទេសថ្មីអស់ទៅហើយ ចាស់ៗជាច្រើនសង្ឃឹមលើកការថែទាំរបស់កូនចៅនឹងមជ្ឈមណ្ឌលថែរមនុស្សចាស់ដើម្បីរក្សាសុខភាពដ៏ពិបាករបស់ខ្លួនឱ្យអាចរស់បាន។ ហេតុដូច្នេះហើយបានជាមានសេចក្តីត្រូវការអ្នកឯកទេសភាសាខ្មែរ ដែលមានជំនាញខាងសុខភាពច្រើនជាងពេលណាទាំងអស់។ អ្នកផ្តល់សេវាសុខភាពនៅតំបន់ឡូវែល នឹងនៅលីន តែតែស្វែងរកបុគ្គលិកនិយាយភាសាខ្មែរ តាំងពីអ្នកជួយថែរ-សុខភាពនៅផ្ទះ រហូតដល់គិលានុបដ្ឋាក នឹងវេជ្ជបណ្ឌិត ដើម្បីផ្តល់ការថែរជម្ងឺ ប្រកបដោយការសម្របតាមវប្បធមិដ៏រសើបជូនដល់ភ្ញៀវជាអ្នកជម្ងឺ។

ដោយសារតែកត្តានឹងការប្រឈមមុខក្នុង

តទៅទំព័រទី ១៤

DRACUT FAMILY
DENTAL

TOP DENTISTS 2018 AWARDED BY BOSTON MAGAZINE

ពេទ្យធ្មេញប្រចាំគ្រួសារនៅដ្រេខិដ

ផ្ដើមបើកហើយ នៅថ្ងៃទី១ ខែមិនា
ហៅមកចុះឈ្មោះជួបគ្រូពេទ្យឥឡូវ នឹងទទួលបានប្រអប់សំអាតធ្មេញមួយ ដោយឥតគិតថ្លៃ

**Grand Re-Opening March 1st**

pre-book your appointment Now and receive a free whitening kit



យើងនិយាយភាសាខ្មែរ
We speak Cambodian
យើងទទួលយក"ឥនស៊ូរិន"ធំៗ ស្ទើរតែទាំងអស់
Major insurances accepted

Dracut Family Dental
14 Loon Hill Road
Dracut, MA 01826

978-955-9005
dracutdental@gmail.com

# 40th Year Anniversary: Remembering The Fall Of Khmer Rough Regime January 7, 1979

by Soben Pin

Stepping into 2019, I like to remind our readers of some important benchmark in Cambodian history. It is a year for all the Cambodian people around the world to pause and observe the 40th anniversary of the fall of the Khmer Rouge in Cambodia, a regime that killed nearly a quarter of its own population between 1975 and 1979 through execution, starvation, and disease in labor camps. That dark history period led many Cambodian people to flee the country and live where they are today. On January 7, 1979, in the wake of the fall of the Khmer Rouge regime, hundreds of thousands of people fled to Thailand's borders to seek refuge in any Western country that would take them. Many ended up in France, United States, Australia, New Zealand and Canada.


First Cambodian Refugee Monument in the U.S erected in front of Lowell's City Hall in 2017

As a result of this migration, in 1980 when the United State Census counted the Cambodians for the first time, there were 16,044 Cambodian people in the United States, half of whom had been admitted as refugees.

The Refugee Act of 1980 allowed many more Cambodians to be admitted to the United States and the migration increased sharply to 149,049 over the next decade. By 2010, the census found 276,667 people of Cambodian descent are living in the United States.

In Massachusetts, the same Census showed 25,387 Cambodian residents, the second largest concentration in America after California.

Similar to Vietnamese or Jewish people who fled their homes unexpectedly because of fear of execution, the Cambodians came with a backpack on their shoulders with little or no clothes and no money with which to start their new lives in America. However, unlike members of many other ethnic groups who migrated to the U.S. with existing communities here to help them settle and transition to the American way of life, the Cambodian migrants were all new arrivals who arrived here at the same time. They had little to no re

Continued to Page 12


## KhmerPost USA, LLC
## សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក

អគ្គនាយក សុបិន្ត ពិន



Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
sobenpin@khmerpost.us

អ្នកនិពន្ធ ខ្មែរ Khmer Editorial
និពន្ធនាយក ពិន សំខុន



Roger Samkhon Pin, Co-founder|Editor
(978-942-1641| rogerpin@khmerpost.us

ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន
Advertising Contact
Soben Pin
Cell: 979-656-8141
sobenpin@khmerpost.us

អ្នកនិពន្ធកិត្តិយស Staff Writer| Translator
Sokharath Koy

ច្នៃសោភ័ណ្ឌភាព Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA



LOWELL POLICE DEPARTMENT

Community Relations Council: LPD Recruiting & Hiring

Superintendent Richardson invites community members to attend an informational session about the Civil Service process, recruiting and hiring.

Date: January 31, 2019

Time: 5:30 PM - 7:30 PM

Location: Middlesex Community College Federal Building 50 Kearney Square, Lowell, MA

For more information, please contact Maryann Ballotta at 978-674-1903 or mballotta@lowellma.gov

Stay Connected with the LPD!

@LowellPD Like @LowellMAPD lowellmapolice

តមកពីទំព័រទី ០១

# ខ្ញុំស្រម័យឃើញ...”របស់ ម៉ាទីន លូទ័រ...

ខ្មៅដិបូងបង្អស់ កាលពីនៅឆ្នាំ២០០៨ គឺប្រធានា ធិបតី បារ៉ាក់ អូបាម៉ា ដែលបានកាន់ដំណែង៨ឆ្នាំ ជាសញ្ញានៃជោគជ័យជាបញ្ចប់របស់ការតស៊ូដ៏ស្វិត ស្វាញផ្ដើមដោយ ម៉ាទីន លូទ័រ ឃីង នោះ។

ករណីនោះបានធ្វើឱ្យខ្ញុំនឹកឃើញដល់មនុស្សម្នាក់ជាតិខ្មែរ ឈ្មោះ កែម ឡី ដែលជាបណ្ឌិតម្នាក់ បានក្រោកឈរប្រឆាំងនឹងរបបផ្ដាច់ការនិយមនៅកម្ពុជា ដោយគ្មានតក់ស្លុត លោកបានបកអាក្រាតអំពើអយុត្តិធមិ និយាយពន្យល់ពលរដ្ឋពីរបបប្រជាធិបតេយ្យ ណែនាំឱ្យថ្នាក់ដឹកនាំចេះយកចិត្តទុកដាក់ថែរទាំនឹងកាពារពលរដ្ឋខ្លួនឯង អប់រំពីភាពសុច្ចរឹតទៀងត្រង់ ចុងបញ្ចប់លោកបានបង្ហាញពីរបៀបទ្រទង់ប្រជាពលរដ្ឋថ្នាក់”មូលដ្ឋានឃុំសង្កាត់” ដែលជាគន្លឹះនៃជោកជ័យអភិវឌ្ឍន៏របស់ប្រទេសកម្ពុជាទាំងមូល ហើយដែលគំនិតនេះ ខាងគណបក្សសង្គ្រោះជាតិដ៏ធំបំផុតនៅកម្ពុជា បានផ្ដល់កិត្តិយសយក”មូលដ្ឋានឃុំសង្កាត់”ធ្វើជាមូលដ្ឋាននយោបាយរបស់គណបក្សនឹងអាចក្លាយជានយោបាយរបស់ជាតិនៅពេលដែលគណបក្សសង្គ្រោះជាតិនឹងឈ្នះឆ្នោត ។ កូនស្រីលោក កឹម សុខា ជាប្រធានគណបក្សសង្គ្រោះជាតិ បាននិយាយនៅឡូវែលនេះថា”បណ្ឌិត កែម ឡី ទើបនឹងចូលមកជួយគណបក្សសង្គ្រោះជាតិ ក្នុងនាមជាសមាជិក មិនបាន១សប្ដាហ៍ផង ក៏ត្រូវគេលួចសម្លាប់យ៉ាងកំសាកបំផុត...។ ទោះជាស្លាប់ទៅហើយក្ដីលោក កែម ឡី បានក្លាយទៅជានិម្មិតរូបជាអ្នកតស៊ូ ដើម្បីសេចក្ដីចំរើនរបស់កម្ពុជានឹងប្រជាពលរដ្ឋខ្មែររួចទៅហើយ ហើយ “ភ្លើងតស៊ូរបស់លោក”នោះ ក៏កំពុងតែទទួលការឆេះបន្តពីមនុស្សជំនាន់ក្រោយទៅយ៉ាងសកម្មរួចទៅហើយដែរ...

ម៉ាទីន លូទ័រ ឃីង បានត្រូវប្រជាជាតិអាមេរិកាំងរំលឹកពីគុណសម្បត្ដនៃការតស៊ូដើម្បីសិទ្ធីពលរដ្ឋនៅថ្ងៃកំណើតរបស់លោក គឺថ្ងៃ១៥មករា១៩២៩ ដោយឱ្យបានឈប់សម្រាកពិកាងារ១ថ្ងៃ ដែលជាថ្ងៃកើនចំនួនមនុស្សរាប់លាននាក់ ពណិសម្បុរថ្មីញញឹមដាក់គ្នា រីករាយជាមួយគ្នា ចូលមកជួយបង្កើនកិទ្យានុភាពនឹងកាពារសហរដ្ឋអាមេរិកជាមួយគ្នា ដែលជាអត្ថន័យ “ខ្ញុំស្រម័យឃើញ...” របស់លោកបណ្ឌិត ម៉ាទីន លូទ័រ ឃីង នោះឯងហើយ។



បណ្ឌិត កែម ឡី អ្នកវិភាគលើបញ្ហាសង្គមបានត្រូវគេសម្លាប់



ប្រជាពលរដ្ឋជាច្រើននៅចងចាំសកម្មភាពស្នេហាជាតិរបស់លោក


មណ្ឌលពិនិត្យសុខភាពលីន LYNN PRIMARY CARE CENTER
វេជ្ជបណ្ឌិត សុខារិទ្ធិ ម៉ី DR. SOKHARITH MEY, MD
(781) 780-7755









មានទទួលអ្នកជំងឺថ្មី

Now Accepting New Patients
Family Medicine for Men, Women, and Children
Behavioral Health - Individual and Group Counseling
Evening & Weekend hrs available
We accept MassHealth, Medicare and other health insurances
Our staff speak Khmer

280 Union St. Unit 402 Lynn, MA 01901
ផ្នែកជំងឺទូទៅ សំរាប់បុរស ស្ត្រី និងកុមារ
ផ្នែកជំងឺផ្លូវចិត្ត ផ្ដល់ប្រឹក្សាមួយទល់មួយនិងជាក្រុម
ក្រុមគ្រូពេទ្យមានបទពិសោធន៍ជាច្រើនឆ្នាំ
ធ្វើការបំរើសុខភាពក្នុងសហគមន៍ខ្មែរ ទីតាំងល្អនិងមានចំណតរថយន្ត
ឥតគិតថ្លៃ បើកពេលយប់ និងចុងសប្ដាហ៍

# REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY WITH

## COST EFFECTIVE NEWSPAPER ADVERTISING

KhmerPost USA

**PUBLISHING**

*Two Issues Every Month*

**READERSHIP**

*50,000 Monthly*
*600,000 Annually*

**DISTRIBUTION**

***70+ Locations in Lowell, MA***
***7,000 copies per month***

***25 Locations in Lynn & Revere, MA***
***1,000 copies per month***

***25 Locations in Providence & Cranston, RI***
***2,000 copies per month***




### *Khmer Post USA Distribution Locations:*

- *Households*
- *Markets*
- *Retail Businesses*
- *Restaurants*
- *Office Buildings*
- *Government Offices*
- *Chamber of Commerce*
- *Buddhist Temples*
- *Laundromats*
- *And Much More*

| | |
|---|---|
| 7Jan and 21 | 8 July and 22 |
| 4 Feb and 18 | 5 Aug and 19 |
| 4 March and 18 | 9 Sept and 23 |
| 8 April and 22 | 7 Oct and 21 |
| 6 May and 20 | 9 Nov and 23 |
| 10 Jun and 24 | 6 Dec and 20 |

***Advertising deadlines are 5 business days prior to printing date.***

KhmerPost USA is a free Cambodian-English biweekly newspaper serving Lowell, Chelmsford, Tyngsboro, Lynn and Revere, MA as well as Cranston and Providence, RI.

It was founded in 2007 by Soben Pin and partner Roger Pin. In 2010, they relocated the newspaper to Lowell to meet the demand for readership.

With an annual readership of 600,000, it is the only premier voice for the Cambodian-American community across the New England region.

**www.khmerpost.us**

**ព័ត៌មានពីកម្ពុជា**

# អង្ករកម្ពុជា

ដោយ ពិន សំខុន

អង្ករកម្ពុជា:

"សភាសហព័ន្ធអឺរ៉ុប" បានសម្រេចកាលពីថ្ងៃទី១៦មករា ២០១៩ នេះ ឱ្យ "យកពន្ធរយពេល ៣ឆ្នាំ" លើការនាំអង្ករពីប្រទេសកម្ពុជានឹងប្រទេសភូមា ចូលមកអឺរ៉ុប ដែលករណីនេះធ្វើឱ្យកម្ពុជាមានការខកចិត្តយ៉ាងខ្លាំង។ លោក សុង សារ៉ន ដំណាងឱ្យភាគីកម្ពុជាបាននិយាយប្រាប់វិទ្យុ "RFI" នាឆ្នាំទី១,១៥០ដុល្លានាឆ្នាំទី២ នឹង១២០ដុល្លា នាឆ្នាំទី៣។

កម្ពុជាធ្លាប់បានទទួលការអនុគ្រោះពន្ធពីសហភាពអឺរ៉ុប តែដោយសារនយោបាយកម្ពុជាបានក្លាយទៅជាតឹងតែង ដោយការរំលោភសិទ្ធមនុស្សនឹងរំលាយលិទ្ធិប្រជាធិបតេយ្យកាលពីឆ្នាំ ២០១៧-១៨មក នយោបាយនោះក៏មានឥទ្ធិពលលើការរកស៊ីរបស់ប្រទេសខ្លួនឯង ហើយសភាអឺរ៉ុប




បារាំងថា "សហភាពអឺរ៉ុបធ្វើនេះ គឺចង់សម្លាប់ប្រជារាស្ត្រខ្មែរក្រីក្រខិតខំរកស៊ីដើម្បីចិញ្ចឹមជីវិតហើយ"។

កម្ពុជាបាននាំអង្ករ៨០ម៉ឺនតោនចេញពីកម្ពុជា ហើយ៤០% ត្រូវបាននាំចូលទៅសហភាពអឺរ៉ុប ដែលរួមប្រជុំដោយប្រទេសចំនួន២៨។ សហភាពអឺរ៉ុប នៅពេលបោះឆ្នោតអនុញ្ញាតិឱ្យនាំអង្ករកម្ពុជានឹងភូមាចូល បានសម្តែងថា "អង្ករនៃប្រទេសទាំង២នេះ ប្រជែងនឹងនឹងផលិតផលក្នុងស្រុករបស់គេ "ហើយ គេក៏រឹតតម្លៃពន្ធ១៧០ដុល្លាក្នុង១តោន ក៏បានព្រមានរួចហើយដែរ។

ប្រទេសភូមាក៏នៅមានលក្ខណៈនយោបាយស្រដៀងគ្នានឹងកម្ពុជាដែរ បើទោះជាអ្នកស្រី អូន សាំងស៊ូជីប្រុខរដ្ឋាភិបាល "សេរី" ខិតខំទប់ស្កាត់ការប្រើលទ្ធិផ្តាច់ការ លើពួកជនជាតិភាគតិចរបស់ខ្លួនក៏ដោយក្តី ប៉ុន្តែគណបក្សយោធាភូមា នៅតែមានអំណាចស្របច្បាប់លើធម្មនុញ្ញប្រទេសភូមានៅឡើយ។

# ជួបជុំនឹងសហគមន៍ខ្មែរនៅជាយក្រុងពារីស

ដំណាងសហគមន៏ខ្មែរនៅទីក្រុង "ទ័រស៊ី" ជាយរដ្ឋធានីបារាំង ប្រមាណ៣០នាក់ បានមកជួបប្រជុំគ្នាតាមសេចក្តីអញ្ជើញរបស់លោកដំណាងរាស្ត្រ


លោក យ៉ែម ប៉ុញ្ញារិទ្ធ

ខ្មែរ យ៉ែម ប៉ុញ្ញាឬទ្ធ នឹងលោក ហាម ប៊ុនឆាយ ប្រធានសមាគមគាំទ្រគណបក្សសង្គ្រោះជាតិប្រទេសបារាំង នៅភោជនីយដ្ឋាន "រ៉ូយ៉ាលទ័រស៊ី" កាលពីថ្ងៃទី៥ មករា២០១៩ ដើម្បីជាកិច្ចជួបជុំគ្នានាឱកាសឆ្នាំថ្មីផង នឹងស្តាប់សេចក្តីរាយការពីស្ថានការវិវត្តន៍នយោបាយខ្មែរពីលោក យ៉ែម ប៉ុញ្ញាឬទ្ធិ នឹងជួបប្រស្រ័យជាមួយ ពិន សំខុន ដែលនាំដំណឹងពីពលរដ្ឋឡូវែលផង ។

សមាគមលោក ហាម ប៊ុនឆាយ គាំទ្រការដឹកនាំនយោបាយលោក យ៉ែម ប៉ុញ្ញាឬទ្ធិ ឱ្យធ្វើកិច្ចការក្រៅប្រទេសស៊ិចង្វាក់គ្នាជាមួយកូនស្រីលោក កឹម សុខា ប្រធានគណបក្សសង្គ្រោះជាតិ ជាប់ឃុំឃាំងនៅគេហដ្ឋានរបស់លោកឯកម្ពុជា គឺនាង កឹម មនោវិទ្យា នាយករងកិច្ចការក្រៅប្រទេសគណបក្សសង្គ្រោះជាតិ, តែពួកគេបានសម្តែងការ "មិនគាំទ្រកិច្ចប្រជុំថ្ងៃទី២ធ្នូ២០១៨" ដែលបានលើកលោក សម រង្ស៊ី ជាប្រធានស្តីទីគណបក្សសង្គ្រោះជាតិនោះទេ។

លោក ប៉ុញ្ញាឬទ្ធិ បានរំលឹកអំពីសកម្មភាពជួបអ្នកនយោបាយរបស់លោកថា "សហគមន៏អន្តរជាតិ មានការយឺតយ៉ាវក្នុងការដាក់គំនាបសង្កត់ទៅកម្ពុជា, សហរដ្ឋអាមេរិកគេពុំបានអនុម័តច្បាប់បង្កកទ្រព្យធុនអ្នកបំផ្លាញប្រជាធិបតេយ្យនៅកម្ពុជានាឆ្នាំមុន ឥឡូវត្រូវយកច្បាប់ដដែលនោះ មកឱ្យដាក់ឱ្យសភាឆ្នាំថ្មីអនុម័តម្តងទៀតទើបបញ្ជូនឡើងទៅទៀតបាន, ចំណែកឯសភាអឺរ៉ុបវិញ ក៏ដូចគ្នាដែរ តែខ្ញុំនៅតែសង្ឃឹមថា "សហគមន៏អន្តរជាតិ គេនឹងមិនបំភ្លេចកម្ពុជាទេ ។ លោក ហាម ប៊ុនឆាយ រាយការពីសកម្មភាពសមាគមក្នុងកិច្ចការពារសិទ្ធិមនុស្សនឹងប្រជាធិបតេយ្យនៅកម្ពុជា តាមរយគណបក្សសង្គ្រោះជាតិ ហើយលោកសម្តែងការរីករាយនឹងស្វាគមន៏ដល់សម្ព័ន្ធភាពដែលនាំមកជាមួយ ពិន សំខុន ប្រតិភូមកពីឡូវែល។

សមាជិការនឹងសមាជិកអង្គប្រជុំថ្ងៃនេះ សុទ្ធសឹងជាអ្នករស់នៅក្នុងតំបន់ទ័រស៊ី-ឡូញ-ន័រស៊ីយែល-ណ័រស៊ីឡឺ ក្រង់លាតសន្ធឹងប្រមាណ៥០គីឡូម៉ែត្រ ខាងកើតក្រុងប៉ារីសរហូតដល់ឱទ្យាន "ឌីស្នេឡិន-Disneyland" ដែលជាតំបន់សម្បូរសហ


លោក ហាម ប៊ុនឆាយ និងសមាជិកសង្គ្រោះជាតិ នៅប៉ារីស

គមន៍ខ្មែររស់នៅច្រើនជាងគេបង្អស់ នាប្រទេសបារាំង, សហគមន៏ខ្មែរបានមកតាំងទីតាំងពីជាង ៣០-៤០ឆ្នាំមកហើយ។ នៅទីនោះ មានសម្បូរដោយពាណិជ្ជកម្មអាស៊ីធំៗ មានភោជនីយដ្ឋានមានសមាគមវប្បធម៌ខ្មែរ ជាច្រើនក្នុងតំបន់ផង -មានមន្ត្រី ពាណិជ្ជករ អ្នកឯកទេសចំណានៗ បានមកទិញផ្ទះសម្បែង រស់នៅជួបជុំគ្នាដូចជាក្រុងខ្មែរមួយដែរ។



# មេធាវីថមាសស្ទីលីអាណូស

- ជួយធ្វើតាក់ដោយមិនបាច់មានលេខសូស្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្តាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្តីប្រពន្ធ ឬគូរដណ្តឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្តីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិដល់សាមីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

# Thomas Stylianos Law Offie

## 287 Appleton Street, Suit 205 Lowell, MA 01852

## Tel: 978-459-5000

## E-mail: Tom@stylianoslaw.com

Attorneys' only licensed in Massachusetts

# ជួបបញ្ហាបង់ថ្លៃកម្ដៅ?

## កម្មវិធីជំនួយឥន្ធនៈអាចជួយអ្នកបាន!*

*អាចមានលក្ខខណ្ឌខ្លះ

រាល់ឆ្នាំអង្គការ Community Teamwork ផ្ដល់ជំនួយឥន្ធនៈដល់១២,០០០លំនៅដ្ឋាន ដែលជួបបញ្ហា ដោយសារចំណាយច្រើនលើថ្លៃកម្ដៅ

COMM UNITY TEAM WORK





| ទំហំគ្រួសារ | ប្រាក់ចំណូល |
|---|---|
| 1 | $ 35,510 |
| 2 | $ 46,437 |
| 3 | $ 57,363 |
| 4 | $ 68,289 |
| 5 | $ 79,215 |
| 6 | $ 90,141 |

### សូមទាក់ទងដើម្បីណាត់ជួប

សូមទាក់ទងដើម្បីណាត់ជួប
ទូរស័ព្ទលេខ៖ ៩៧៨ ៤៥៩ ៦១៦១
អ៊ីនធើណិត៖ www.commteam.org
ចុចលើពាក្យ Fuel Assistance ពណ៌ខៀវ នៅលើគេ ខាងស្ដាំដៃ

ជំនួយនេះផ្ដល់តាមសហគមន៍ដូចខាងក្រោម

Arlington | Groton
Bedford | Lexington
Belmont | Lowell
Billerica | Pepperell
Burlington | Tewksbury
Carlisle | Tyngsboro
Chelmsford | Waltham
Dracut | Watertown
Dunstable | Westford
Wilmington

ការផ្សព្វផ្សាយនេះ គឺមានការជួយឧបត្ថម្ភពីកម្មវិធីជំនួយផ្នែកថាមពលសម្រាប់គ្រួសាមានចំណូលទាបតាមរយៈថវិការដែលបានមកពីក្រសួងអភិវឌ្ឍន៍សហគមន៍ និងលំនៅដ្ឋានម៉ាសាឈូសេត។

"នយោបាយកម្ពុជា"

# សម រង្ស៊ី ទទួលការគាំទ្រពីគណៈអចិន្ត្រៃយ៍គណបក្សសង្គ្រោះជាតិ

ខ្មែរផុសស.រ.អា.

ដូចលោកស្រី មួ សុខហួរ អ្នកដំណាងរាស្ត្រ គណបក្សសង្គ្រោះជាតិបានសន្យាថា"នឹងបញ្ចុះបញ្ចូលគណអចិន្ត្រៃយ៍ឱ្យទទួលយកលោក សម រង្ស៊ី..." ថ្ងៃទី២១មករា ២០១៩ នៅសាលប្រជុំសាលាក្រុងឡូវែល មានកិច្ចប្រជុំមួយមួយដែលគេឱ្យឈ្មោះថា ជា"កិច្ចប្រជុំប្រវត្តិសាស្ត្រ"របស់គណបក្សសង្គ្រោះជាតិ គណអចិន្ត្រៃយ៍របស់បក្ស (១៥នាក់មានវត្តមានក្នុងអង្គប្រជុំនឹងប្រយោលក្នុងចំណោម២៤រូប) បានបើកកិច្ចប្រជុំមួយ ក្រោមអធិបតីភាពនៃលោក សម រង្ស៊ី ប្រធានស្តីទី ដើម្បីអនុម័ទលើសេចក្តីសម្រេចយកសន្និសិទកាលពីថ្ងៃទី២ធ្នូ នៅ"អាតឡង់តា"ជាបានការ -នៅក្នុងនោះក៏មានសេចក្តីសម្រេចយកលោកសម រង្ស៊ី ជាប្រធានស្តីទី តែមិនបានតម្លើងអនុប្រធាន(មាន៣រូប) ណាម្នាក់ជំនួសឱ្យលោក កឹម សុខា ដែលកំពុងជាប់ការឃុំខ្លួននៅផ្ទះរបស់លោកនោះទេ។

គណអចិន្ត្រៃយបានសម្រេចករណីសំខាន់មួយទៀត គឺអនុញ្ញាត្តិឱ្យលោក សម រង្ស៊ី ចូលទៅប្រទេសកម្ពុជាវិញ នៅអនាគតខាងមុខតែមិនច្បាស់ជាមុនខែមិនា ដូចដែលបាននិយាយនោះទេ -លោក អេង ឆាយអៀង អនុប្រធាននិយាយថា "គណបក្សនឹងរៀបដំណើររបស់លោក សម រង្ស៊ី ដោយឱ្យមានសមាជិកសមាជីកាមកទទួលឱ្យបានកុះករជាមុនសិន។ ក្នុងសេចក្តីសម្រេចករណីផ្សេងៗទៀត ថ្វីត្បិតតែអង្គប្រជុំមិនបានចាត់ទុកថា លោក



កិច្ចប្រជុំប្រវត្តិសាស្ត្ររបស់ជាមួយលោក សម រង្ស៊ី

កឹម សុខា ជាប់ក្នុងការឃុំឃាំងមិនអាចមានសម្បទាគ្រប់គ្រាន់នឹងសម្រេចការអ្វីក៏ដោយអង្គប្រជុំនៅតែទាមទាឱ្យមានការដោះលែងលោក កឹម សុខា ជាបន្ទាន់ដោយគ្មានលក្ខខណ្ឌដែរ។

ប្រតិកម្មភ្លាមៗពីក្រុមសង្គ្រោះជាតិសហរដ្ឋអាមេរិកនឹងប្រទេសបារាំង គេមិនបានទទួលស្គាល់សមាសភាពលោក សម រង្ស៊ី ជាប្រធានស្តីទីថ្មីនោះទេ ដោយគេយល់ថាជាការតម្លើងតួរនាទីដោយមិនស្របលក្ខន្តិកៈគណបក្ស ហើយម្យ៉ាងទៀតលោក សម រង្ស៊ី បញ្ចុះបញ្ចូលតែជាមួយបក្សពួករបស់លោក ដូចដែលធ្លាប់ធ្វើពីអតីតកាលមកហើយ ដូចជារក្សាឱ្យមាន CNRP-NA របស់លោក ទោះជាមានគណបក្សសង្គ្រោះជាតិជាចលនាបង្រួបបង្រួមជាតិហើយក៏ដោយ។ ពីភ្នំពេញឯណោះវិញ លោក ហ៊ុន សែន ព្រមទាំងអ្នកនាំពាក្យរដ្ឋាភិបាលពានស្វាគមន៍គំនិតចង់ត្រឡប់មកកម្ពុជាវិញរបស់លោក សម រង្ស៊ី ថានឹងយក"គុកនឹងខ្នោះ"មកទទួលទៅវិញ។

គួររំលឹកថា គណបក្សសង្គ្រោះជាតិមានក្រុមអ្នកគាំទ្រនៅក្រៅប្រទេសពាសពេញពិភពលោក ដែលនៅសហរដ្ឋអាមេរិកនេះ មានឈ្មោះថា CNRP-USA – CNRP-Fr – CNRP-Canada" ដែលទទួលបាននូវការគាំទ្រជាផ្លូវការពីលោក កឹម សុខា នឹង លោកសម រង្ស៊ី រួមគ្នា ប៉ុន្តែ លោក សម រង្ស៊ី នៅរក្សាអង្គការគាំទ្រលោកផ្ទាល់ទន្ទឹមគ្នាមួយទៀតមានឈ្មោះថា CNRP-NA ដែលនៅក្រោមបញ្ជាតែពីក្រុមលោក សម រង្ស៊ី តែម្ខាងប៉ុណ្ណោះ នៅឯបរទេសជារៀងរហូតមក បើទោះជាមានការច្របាច់ចូលគ្នាជាសង្គ្រោះជាតិតែមួយក៏ដោយក្តី -គឺក្រុម១ខាងក្រោយនេះហើយ ដែលកំពុងតែរៀបចំជូនលោក សម រង្ស៊ី ឱ្យត្រឡប់មកកាន់ដំណែងប្រធានស្តីទីវិញ នឹងរៀបចំឱ្យចូលទៅកម្ពុជាវិញ ដោយមិនចាំបាច់ការព្រមព្រាងគ្នាពីលោក កឹម សុខា បច្ចុប្បន្នជាប្រធានគណបក្សនោះទេ។ កូនស្រីលោក កឹម សុខា គឺនាង គឹម សម្ធាធីតា និយាយថ្មីៗនេះនៅឡូវែលថា "លោកប្រធានជាឪពុករបស់នាងបានដឹងពីរឿងរ៉ាវទាំងឡាយ ដែលកើតឡើងនៅក្រៅប្រទេសទាំងអស់ដូចយើងរាល់គ្នាដែរ"។







# រនាំងអន្តោប្រវេសន៍មិនបានសង់ តើត្រូវបន្ទោសនរណា?

ដោយ ពិន សំខុន

ចុងសប្តាហ៍ទី១១មករានេះ គឺជាសប្តាហ៍ដែលប្រាក់បៀវត្សទី១របស់អ្នករដ្ឋការអាមេរិកាំងមិនបានទទួលដោយសារតែរដ្ឋបាលសហព័ន្ធបានត្រូវបិទទ្វារ (ចាប់តាំងពីថ្ងៃទី២២ខែធ្នូ២០១៨មក) ពីព្រោះតែ"រនាំងអន្តោប្រវេសន៍" ដែលលោកប្រធានាធិបតី ដណល ត្រម ទាមទារឱ្យសភាយល់ព្រមផ្តល់ថវិការ៥ពាន់លានកន្លះ ដើម្បីបញ្ចប់គម្រោង តែសភាអាមេរិកាំងមិនព្រមឱ្យមកទល់ ថ្ងៃទី១៥មករា២០១៩ទៅហើយ នៅគ្មានសញ្ញាថា នឹងត្រូវបញ្ចប់បាននៅឡើយទេ។ តើករណីនេះនឹងប៉ះពាល់អ្វីខ្លះ?

រដ្ឋបាលអាមេរិកាំងត្រូវបិទទ្វារ បានន័យថាៈ អ្នករដ្ឋការអាមេរិកាំង៨ម៉ឺននាក់ មិនបានទទួលប្រាក់ខែ កងសន្តិសុខតាមព្រំប្រទល់ដែន នឹងតាមប្រលានយន្តហោះត្រូវគាំងដំណើរ (អាកាសយានដ្ឋានខ្លះត្រូវបិទទ្វារ ដោយខ្វះបុគ្គលិកសន្តិសុខ) បុគ្គលិកត្រួតពិនិត្យសុខភាព មានចំណីអាហារ-មានការត្រួតពិនិត្យចាំបាច់នានា ក៏ត្រូវផ្អាកដំណើរការ, បុគ្គលិករដ្ឋបាលខាងពន្ធដារ ក៏មិនមានមនុស្សធ្វើការគ្មាននរណាឆ្លើយនឹងសំនួរចាំបាច់របស់អ្នកបង់ពន្ធ នាឱកាសធ្វើពន្ធដើមឆ្នាំ ...គឺពេលនេះហើយដែលសន្តិសុខក្នុងប្រទេសកំពុងប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់បំផុត ដោយភេរវករអាចនឹងជ្រៀតចូលមកធ្វើសកម្មភាព... មិនត្រឹមតែប៉ុណ្ណោះ គ្រួសារអ្នករដ្ឋការដែលមិនបានត្រៀមខ្លួននឹងចំណាយប្រចាំថ្ងៃ អាចប៉ះពាល់ដល់ចំណាយលើឈ្នួលផ្ទះ



សេតវិមានជួបចចារជាមួយគណបក្សប្រឆាំង



លោកស្រី ប៉ូលូហ្ស៊ី

ឈ្នួលរថយន្ត ខ្លះប៉ះពាល់ដល់ម្ហូបអាហារក្នុងគ្រួសារថែមទៀតផង... ថែមពីលើនេះទៅទៀត មានពាណិជ្ជករខ្លះ រស់នៅដោយសារជួញដូរជាមួយមន្ត្រីរដ្ឋការទាំងនោះ ក៏ឃើញមុខរបររបស់ខ្លួនស្រុតចុះមួយប៉ប្រិចភ្នែក គួរឱ្យបារម្ភ,... អ្នកយកព័ត៌មានគ៏ផ្តើមរាយការពីបាតុកម្មគ្រួសារអាមេរិកាំងដែលខ្វះខាតមុខក្រោយដោយសារតែការប្រទាញប្រទង់នយោបាយរបស់ប្រធានាធិបតី ឌុណល ត្រម នឹងសភាជាតិដែលភាគច្រើនជាគណបក្សប្រជាធិបតេយ្យ... តើត្រូវបន្ទោសនរណា?

ប្រជាពលរដ្ឋអាមេរិកាំង៥៥%បន្ទោសថា "មកពីលោកប្រធានាធិបតី ដណល ត្រម ទាមទររហូសហេតុពេក" ចំណែក៣៦%បន្ទោសថា "មកពីគណបក្សប្រឆាំងមិនព្រមឱ្យថវិការតាមសំណើរ" រីឯអ្នក៩5ទៀត គេនិយាយថា "មកពីអ្នកទាំងពីរមិនព្រមចុះសម្រុងគ្នា"... ដូច្នេះថ្វីត្បិតតែពួកអា-មេរិកាំងភាគច្រើន បានបោះឆ្នោតឱ្យ ដណល ត្រម ក៏ដោយក្តី គេមិនបានឱ្យតម្លៃដល់"ជញ្ជាំងអន្តោប្រវេសន៍" ថាត្រូវតែឱ្យលោក"ត្រម"រក្សាពាក្យសន្យាហួសហេតុពេកនោះទេ -អ្នកបោះឆ្នោតភូមិភាគខាងជើង ដែលសុទ្ធតែជាអតីតអ្នកកាយយកធ្យូងថ្ម នឹងជាអ្នកបោះឆ្នោតឱ្យលោក"ត្រម" ឥឡូវមានការខកចិត្តច្រើន គេថាលោក"ត្រម"បានភូតភរពួកគេ ពីការដែលធ្វើឱ្យអណ្តូងធ្យូងថ្ម ដែលបានតទៅទំព័រទី ១២បិទទ្វារជាយូរមកហើយ នោះឱ្យដើរឡើងវិញ ដើម្បីឱ្យមានកាងារធ្វើគ្រប់គ្នា តែអ្នកឯកទេសបញ្ជាក់ថា "មិនអាចធ្វើឱ្យដើរឡើងវិញបានទេ" ពីព្រោះតម្លៃផលិតនោះ វាថ្លៃជាងថាមពលឯទៀតៗ ច្រើនណាស់ តទៅទំព័រទី១២


## មកទេសចរណ៍រដូវស្លឹកឈើជ្រុះនៅតំបន់ម៉ារីម៉ាក់វ៉ាលេ

គ្រាន់តែធ្វើដំណើរតែកន្លះម៉ោងប៉ុណ្ណោះពីទិសពាយព្យនៃទីក្រុងប៊ូស្តុននឹងមកដល់តំបន់ម៉ារីម៉ាក់វ៉ាលេ។ការផ្លាស់ប្តូររដូវកាលបន្ថែមនៅភាពរស់រវើកនៅតំបន់នេះ។

មានថាមពលអស្ចារ្យដែលមិនអាចប្រកែកបាននៅតំបន់ ម៉ារីម៉ាក់វ៉ាលេ ដែលថាមពលដូចគ្នានេះដែលបានផ្តល់កំណើតដល់ប្រទេសរបស់យើង។ ក្រុងនិមួយក្នុងចំណោម ក្រុង និងទីប្រជុំជនទាំង 12 របស់យើងមានសម្រស់ និងទីកន្លែងប្លែកពីគេដែលលោកអ្នកត្រូវការ,

ដំណើរកម្សាន្តបន្ទាប់របស់លោកអ្នករង់ចាំលោកអ្នកនៅទី

















Greater Merrimack Valley
Convention & Visitors Bureau
adventuresawait
merrimackvalley.org

MASSACHUSETTS
massvacation.com

merrimackvalley.org

សូមចូលទៅកាន់ Twitter និង Instagram @MerrimackValley




## ផ្ដើមសេចក្ដី

អារម្ភកថា

យើងសូមជូនរឿងថ្មីមួយទៀត គឺរឿង"កុមារ យោធិន្ទ"ជាប្រវត្តិកុមារប្រមាណជា១ពាន់នាក់ ដែលបានចូលទៅបំរើក្នុងកងទ័ពតាំងពិអាយុ១០ឆ្នាំ នៅសាលារៀនមួយដែលកងខេមរភូមិន្ទបានបង្កើតឡើងបន្តពីអាណានិគមបារាំងក្នុងបំណងជួយចិញ្ចឹមកូនរបស់កងទ័ពបង្ហាត់បង្រៀនមុខវិជ្ជាដែលឪពុករបស់គេស្រឡាញ់ចូលចិត្តនឹងបានបូជាជីវិត ដើម្បីមាតុភូមិរបស់គេថែមទៀត។

ជារឿងពិតរបស់យុវជនមួយក្រុមរស់នៅដាច់ពីការថ្នាក់ថ្នមរបស់ឪពុកម្ដាយមិនដូចក្មេង ឯទៀត គេចិញ្ចឹមកុមារទាំងនោះ ក្រោមវិន័យតឹងរឹងនៃកងទ័ពបង្ហាត់ហ្វឹកហ្វឺននឹងរៀនសូត្រវិជ្ជាចម្បាំងតាំងតែពីនៅតូច តែសាធារណជនមិនសូវដែលដឹងថា"សាលានោះជាអ្វី?បង្ហាត់បង្រៀនរបៀបណា? នឹងស្គាល់ថា ជាអ្វីនោះទេ" ក្រៅតែពីអ្នកនៅក្នុងក្រុងជាមួយនឹងអ្នកមិនឆ្ងាយពីបន្ទាយនៃកូនទាហ៊ានទាំងនោះ តែប៉ុណ្ណោះដែលស្គាល់ ហើយឱ្យឈ្មោះថា"ពួកក្មេងហ្វូង" ដែលជាឈ្មោះបកប្រែពីពាក្យបារាំងមកថា"Les enfants de troupe"។

# ការរៀបចំរចនាសម្ព័ន្ធសាលាកុមារយោធិន្ទ(ត)

**ពិន សំខុន**

**ភាគ១ - សាលាកងកុមារយោធិន្ទ**

-ម៉ា ឆេង ៦២៣ - សាន សួត ៦៣០ - សូ មាច ៦៣២ - សេត ទ្រី ល្បីខាងកីឡាបាល់ទាត់ ប៊ូ ង៉ូវ - ខាត់ ភុំ - ឆាង ព្រឿង ល្បីខាងកីឡាបាល់ទះ បែន សាន - ស្រី សុខុម -ម៉ៅ យឿន ល្បីខាងកីឡាបាស្កិតបាល់ នឹងហាន់បាល់។ នៅមានក្រុមកីឡា យូដូ ដែលមានអ្នកពូកែរដូចជា ស៊ុម សំផាត នឹងអ្នកហាត់មួយចំនួនទៀត តែពួកនោះគ្មានគូរប្រគួតក្រៅពីក្រុមយោធពលខេមរភូមិន្ទទេ។

មានព្រឹត្តិការអាស្រូវខ្លះ ដែលបានកើតលេចធ្លោឡើង នៅពេលរដូវប្រកួតកីឡាបាល់ទាត់ នាឆ្នាំមួយនោះ(ទំនងជាឆ្នាំ១៩៦៧) រវាងក្រុមកីឡាបាល់ទាត់ផ្ដាច់ព្រាត់ប្រចាំវិទ្យាល័យនៅខេត្រកំពង់ចាម បណ្ដាលឱ្យមានការវាយតប់គ្នារហូតដល់ក្រៅបរិវេណកីឡាដ្ឋានក្រុងទៀតផង...។ ថ្វីត្បិតតែមានការវាយតប់គ្នារវាងក្មេងៗកុមារយោធិន្ទនឹងយុវជនសាលឯទៀតៗ ម្ដងម្កាលក្ដី តែមិនដូលើកនេះទេ គឺនៅពេលដែលក្រុមបាលទាត់កុមារយោធិន្ទបានទាត់ស្មើរគ្នានឹងសាលាវិទ្យាល័យព្រះសីហនុ គេនៅរង់ចាំលទ្ធផលវិទ្យាល័យព្រះសីហនុទល់នឹងវិទ្យាល័យឯកជនឈ្មោះ"វិទ្យាល័យសហជន" ដែលពូកែរគ្រាន់បើ តែមកចាញ់វិទ្យាល័យកុមារយោធិន្ទ"៣ទល់នឹងសូន្យ" ដូច្នេះវិទ្យាល័យព្រះសីហនុនឹងបាន



រូបថតកុមារយោធានៅដាឡាត់

រង្វាន់លេខ១ ត្រូវឈ្នះសាលា "សហជន"ឱ្យលើសពី៣ ទើបបានក្លាយជា"ជើងឯកក្នុងខេត្តកំពង់ចាម"... តែបើឈ្នះ"សហជន"តិចជាង ៣-០ គឺសាលាកុមារយោធិន្ទនឹងបានលេខ១ទៅវិញ... បុន្តែសាលា"សហជន"បានលេងកំប្លែងធ្វើឱ្យចាញ់វិទ្យាល័យព្រះសីហនុរហូតដល់ទៅ ៧-០ពីព្រោះមិនចង់ឱ្យសាលាកុមារយោធិន្ទពានទទួលរង្វាន់លេខមួយ...ដែលជាហេតុធ្វើឱ្យសិស្សកុមារយោធីន្ទខឹងសម្បារយ៉ាងខ្លាំងរហូតដល់លើកគ្នា ទៅតាមវាយក្រុមកីឡាករ "សហជន"នឹងគ្រូបង្ហាត់ឡើងទ្រមខ្លួន ពេលចេញពីទីប្រកួតមកខាងក្រៅ។ ពេលនោះ លោកកុម្មង់ដង់ ទឹម ថូ ក៏មិនសប្បាយចិត្តនឹងឃើញព្រឹត្តិការយ៉ាងនោះដែរ តែខំទប់ចិត្តដាក់ទណ្ឌកម្មកុមានរយោធិនខ្លះៗ មាន ប៊ូ ង៉ូវ -ស៊ីសុវត្ថិ ខារម៉ា... ឱ្យទទួលទោសយ៉ាងស្រាលៗ។ សិស្សកុមារយោធិន្ទធ្លាប់មានប្រវត្តិវាយតបច្រើនគួរសមដែរ តែមានតែសាលាដៃដែក"សាលាតិចណូ"ទេដែលជាគូរប្រកួតស្មើរមុខគ្នាសាលាឯទៀតៗមិនហ៊ានប្រឈមមុខទេ។ ទាំងនោះហើយជាអនុស្សាវរីយដ៏ផ្អែមល្ហែមនឹងជូរចត់នៃសាលាកុមារយោធិន្ទ ដែលពួកគេនាំយកទៅនៅពេលចេញពីសាលាទាំងអាឡោះអាល័យ។

គឺជាពិធីអស្ចារ្យណាស់ ដែលសិស្សម្នាក់ ២ត្រូវការពេលពេញមួយថ្ងៃសម្រាប់ត្រៀមខ្លួនកុំឱ្យភ្លាត់ឱ្យសោះ... មានពេលមួយនោះ កុមារយោធិន្ទ ពិន សំផាន់ អត្តលេខ ៦៦១ ពេលរៀបកន្លែងខ្លួនឯងរួចហើយ ស្រាប់តែឃើញ"ចំពាមកៅស៊ូ"នៅកណ្ដាលវាលមិនទាន់លាក់ ចំពេលដែលកុម៉ង់ដង់មកដល់ទៅហើយ, ទាល់ច្រក ក៏ក្រវែងចំពាមកៅស៊ូនោះ ទៅក្រោមហិបអ្នកនៅជិតគ្នានោះ ដោយសង្ឃឹមថាលោកមេបញ្ជាការនឹងមិនលើកហិបនោះចេញមកទេ...តែហាក់ដូចជាដឹងមុនលោកកុម៉ង់ដង់ដើរមកឈប់ចំហិបនោះ ឆែកមើលការសំអាតកន្លែងយកកន្សែងសរបស់លោកមកជូតកន្ទ្បៀតគ្រែ តែស្អាតអស់ហើយនៅពេលឆែកហិបវិញ ក៏ស្រាប់តែឃើញចំពាមកៅស៊ូ បញ្ជាឱ្យម្ចាស់កន្លែងបង្ហាញខ្លួន កុមារយោធិន្ទ ពិន សំខុន អត្តលេខ ៦២៧បានត្រតូវទទួលទណ្ឌកម្មរត់១០០ជុំ អាគារវែង នាវេលារសៀលដដែលនោះ ក៏ព្រោះតែប្អូនរបស់ខ្លួនបានលាក់ជំពាមនៅទីនោះ មិនថាអ្នកណាជាអ្នកធ្វើទេ ហើយក៏មិនអាចជំទាស់នឹងបញ្ជាបានឡើយ។

ក្នុងចំណោមសិស្ស៣០០នាក់ដែលបានត្រួតពិនិត្យមាន១២នាក់បានទទួលការពិន័យឱ្យរត់ជាជួរជាមួយគ្នា ក្រោមការរាប់ចំនួនជុំដោយសែហ្សង់សែព"ជីម"។ រត់ជុំវិញអាគារដែលមានទំហំ១០០ម៉ែត្រ ពួកគេត្រូវរត់ប្រមាណជា៣ម៉ោង ទើបចប់យ៉ាងវេទនា។

ក្នុង១ឆ្នាំមានវិស្សមកាល២ដង គឺ"វ៉ាកងតូច"មានរយពេល១៥ថ្ងៃ នឹង"វ៉ាកងធំ" មាន៣ខែ ក្នុងពេលនោះសិស្សមានសិទ្ធនឹងបានទៅលេងផ្ទះសម្បែងរបស់ខ្លួនបាន នារយៈពេលពាក់កណ្ដាលវិស្សមកាល, រីឯពាក់កណ្ដាលទៀតជាពេលសម្រាប់សាលាកងកុមារយោធិន្ទបង្ហាត់សិស្សរបស់គេ នូវគ្រប់មុខ"វិជ្ជាជាកងទ័ព" មានមុខវិជ្ជា"ទ្រឹស្ដី" នឹងមុខវិជ្ជា"អនុវត្តន៏"សម្រាប់ឱ្យអាចក្លាយទៅជានាយទាហ៊ានគំរូបាន ។ ពួកគេបានស្គាល់ពីកាំភ្លើងតូច កាំភ្លើងធំ ហាត់ពីផែនទី សំគាល់ផ្លូវនៅទីងងឹតស្គាល់ពីទាហ៊ានជើងទឹកជើងគោក នឹងជើងអាកាសទៀតផង ។

គឺក្នុងរយៈពេលទី២នោះហើយ ដែលសិស្សកុមារយោធិន្ទតែងយកពេលថ្ងៃសៅរ៏នឹងថ្ងៃអាទិត្យ ដែលជាថ្ងៃសម្រាក ទៅដើរលេងដីខ្សាច់"កោះប៉ែន"ទៅស្ទូចត្រីនៅ"បឹងកុក"ទៅកាច់ពោតថ្មីៗទៅទិញឪឡឹក "ចុងកោះ" ឬទៅទិញប៉ិកគក់ទើបមកដល់ថ្មីៗ ទៅលេង"ទន្លេបិត" គឺជាអនុស្សាវរីយកាត់ថ្លៃមិនបានពីខែត្រកំពុងចាមដ៏សម្បូរបែបនឹងស្រស់ប្រិមប្រិយដែលម្នាក់ធ្លាប់រស់នៅច្រើនឆ្នាំទៅហើយ។

ជាមួយគ្នានោះ ខែវិស្សមកាលជាខែក្ដៅ ឆ្នាំ១៩៦៥-៦៦ សិស្សតែងតែចេញទៅលេងបាល់ទាត់ បាល់"បាស្កិត" នៅខាងក្រៅសាលាជួបមិត្រស្រីប្រុសជាហូរហែរ ជាយុវជនមានការអប់រំ មានអនាគតគ្រាន់បើ កងកុមារយោធិន្ទមានស្រីស្រឡាញ់ចូលចិត្តក៏គួរសម។ ពិន សំផុន អត្តលេខ២៩៤ អាយុ១៦ឆ្នាំ ពេញវ័យស្អាតដូចបារាំង ជារាមច្បង"Major" តែងនាំថាសចម្រៀង The Bettles ដ៏ពេញល្បីឈ្មោះ មកចាក់ស្ដាប់ជាញយៗនៅក្នុងបន្ទាយ ដែលនាងកញ្ញា "កាមាលីន"រៀននៅវិទ្យាល័យព្រះសីហនុ ដ៏ទំនើបនិយមឱ្យខ្ចីក្នុងនាមជាមិត្ត មានអ្នកចូលរួមស្ដាប់យ៉ាងអ៊ូអរ។ បន្តិចក្រោយមក បងសំផុន ក៏នាំបទ"កម្ពុជាទ្វីស"របស់សិល្បករ ជុំ កែម ដ៏កំពុងពេញនិយមមកឱ្យស្ដាប់ទៀត... មិនត្រឹមតែស្ដាប់សិស្សទាំងអស់នាំគ្នារាំគ្រវីគូថបង្វិលកែងជើង នៅក្បែរកន្លែង

តទៅលេខក្រោយ

តមកពីទំព័រទី ១០

# រនាំងអន្តោប្រវេសន៍មិនបានសង់...

មានផលិតផល"ឧស្ម័ន់"ជាដើម មិនអាច ប្រជែង-តម្លៃបានទេ, ពួកគេខកចិត្តណាស់ ដោយ លោក ត្រម ផ្តោតអារម្មណ៏ទៅលើ"ជញ្ជាំង"នោះ ច្រើន-ជាងជីវភាពពួលគេ។

ថ្ងៃទី៣១នៃរដ្ឋាភិបាលបិទទ្វារ លោកត្រម នៅតែទាមទារឱ្យសភាគណបក្សប្រជាធិបតេយ្យ "យល់ព្រមផ្តល់ឱ្យថវិការជាមុន ៗនឹងចរចារក ដំណោះស្រាយបញ្ហា"អន្តោប្តវេសន៏" តែសភា ឆ្លើយថា"បើករដ្ឋាភិបាលជាមុនសិន ទើបមានការ ចរចារបាន"។ គ្មានសង្ឃឹមថា នឹងបើកទ្វារឆាប់ៗ នេះបានទេ ដោយគេមិនជឿលោកត្រម បានទៀត ទេ គេនៅតែឆ្ងល់ថា "២ឆ្នាំកន្លងមកហើយ សភា នៅក្នុងដៃគណបក្សសាធារណរដ្ឋ តើហេតុអ្វីក៏មិន ធ្វើ"រនាំងអន្តោប្រវេសន៏"ពេលនោះទៅ? ហេតុអ្វី ក៏រង់ចាំសភាគណបក្សប្រជាធិបតេយ្យទៅវិញ?

នៅបាំង១សប្តាហ៏ទៀតសោះ លុយ "ជំនួយ ម្ហូបអាហារ-Food Stamps"នឹងត្រូវកាត់លុយជួយ ដល់ឈ្នួលផ្ទះអ្នកក្រីក្រក៏នឹងត្រូវលុបចោលជំនួយ ចាំបាច់ឯទៀតៗក៏មានបញ្ហា... ភាពអាសន្នជាក់ ស្តែងនៃរដ្ឋាភិបាល"បិទទ្វារ"នឹងមកដល់ប្រធានា ធិបតីអាមេរីកាំង នៅតែដោះស្រាយបញ្ហាប្រជាជាតិ ដូចជាអ្នកជំនួញដែលភាពអាសន្នទំនងជានៅមិន ឆ្ងាយនោះទេ! ពលរដ្ឋអាមេរីកាំងនឹងរងគ្រោះដោយ សារ តែសម្បូរហួរហៀរពេកជាមិនខាន។



Continued from page 03

# KhmerPost USA January Column

sources and struggled to find their living paths in their new country.

The common barriers of language and culture they faced helped band them together to create a strong new community that rapidly adapted to American life. They became resources for each other and created a unique community around shared food, family, culture, and religious practices.



From places in New England like Lowell and Lynn in Massachusetts and Providence and Cranston in Rhode Island, to Midwestern cities like Houston, Texas to West Coast places like Long Beach, California and places in beween like Chicago, Minnesota, Philadelphia, Virginia, and New York - wherever there are Cambodian people, there is a community in which you will find a Cambodian temple or two, cultural dance groups, community leaders, and small mom and pop stores like grocery markets and restaurants which are important economic engines that support the community.

With the 40th anniversary of the fall of the Khmer Rouge, the KhmerPost USA will focus on sharing with our readers the ways in which the Cambodian diaspora commemorates this important historical milestone. Stay tuned for more on this topic in future editions.


MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ
មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com





CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវ៉េយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- ថៃខឹមប (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY
77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

AccuCare
Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារ៉ាំរ៉ៃផ្នែកសុខភាព ឬជរា ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed**
**for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

តមកពីទំព័រទី ០២

# មនុស្សចាស់ខ្មែរនៅរដ្ឋម៉ាសាឈូសេត

សហគមន៍ខ្មែរទាំងនោះហើយ ក៏ជាឱកាសបង្កើតបានជាឧស្សាហកម្មខាងថែសុខភាពនេះឡើង - គឺគេមានកម្មវិធីអប់រំ រយៈពេលខ្លី សម្រាប់អ្នកដែលចង់រៀនកម្មវិធីសិក្សាសុខភាព នៅមហាវិទ្យាល័យសហគមន៍ក្នុងតំបន់បាន -កម្មវិធីនោះអាចនាំអ្នកសិក្សាទៅទទួលកាងារខាងថែរសុខភាព ដូចជា"Certfied Nurse Assistant"ដែលមានប្រាក់បៀវត្សរ៍៣២,000ដុល្លាក្នុង១ឆ្នាំ ហើយមាន"បេណេផិ្វក"ថែមទៀត។ នៅមហាវិទ្យាល័យ MCC មានផ្តល់កម្មវិធី"Nursing Assistant Certificat" តាមរយៈ Academy of Health Profession នៅ"មជ្ឈមណ្ឌលសុខភាព, វិទ្យាសាស្ត្រនឹងបច្ចេកវិជ្ជា"នៅឡូវែល ។ កម្មវិធីនោះត្រូវការរៀន៨សប្តាហ៍ នៅថ្នាក់រៀន ២ល្ងាចក្នុង១សប្តាហ៍ នឹងនៅព្រឹកថ្ងៃសៅរ៍ បើចង់ដឹងបន្ថែម https// www.middlesex.mass.edu/ahp/

បន្ថែមពីនេះ, កាកបាទក្រហមក៏មានផ្តល់ថ្នាក់CNA រយៈពេញមួយឆ្នាំ ហើយមាននៅគ្រប់រដ្ឋនៃសហរដ្ឋផង -ដោយមិនយកថ្លៃ ឬក៏យកតិចតួចពីអ្នកមកសិក្សា ។ថ្នាក់CNA នៅរដ្ឋម៉ាសាឈូសិតគេរៀនរយៈពេលពី៤-៨សប្តាហ៍-មុននឹងចុះឈ្មោះចូលសិក្សាអ្នកត្រូវបំពេញលក្ខខណ្ឌខ្លះ ដូច្នេះសូមចូលទៅវេបសាយ https;//www.redcross.org/take-a-class បំពេញសំណុំលិខិត"អនឡាញ"ហើយទៅរៀននៅសាលាដែលនៅមិនឆ្ងាយពីអ្នក ។



# January 2019 Scam Alerts

AARP Fraud Watch Network

## Social Security Scams



Acting Inspector General of Social Security, Gale Stallworth Stone, is warning citizens about phone call scams in which impersonators are copying SSA's 1-800 number so that it appears as a legitimate call on a caller-ID screen. These scammers then identify themselves as SSA employees, request a person's Social Security number and threaten to terminate the person's benefits. If you receive a call like this, do NOT provide any personal information. Instead report this scheme by calling 1-800-269-0271 or visit the SSA Office of Inspector General website, https://oig.ssa.gov/report.

## W-2 and Tax Aid Scams




Acting Inspector General of SoAs the tax season approaches, individuals as well as small businesses need to be cautious of identity theft. Identity thieves use stolen Employer Identification Numbers to create fake W-2 Forms to file with fraudulent individual tax returns. Fraudsters also used these to open new lines of credit or obtain credit cards. Now, they are using company names to file fraudulent returns. Employers are warned to lookout for emails asking for sensitive W-2 information. If you believe you have been targeted by a tax scammer, you can report it to dataloss@irs.gov and StateAlert@tacadmin.org.

គ្មានសហបង់ថ្លៃ — ជារៀងរហូត

គ្មានការបង់ថ្លៃសម្រាប់ការណាត់ជួបវេជ្ជបណ្ឌិត គ្មានការបង់ថ្លៃសម្រាប់ការថែទាំធ្មេញ គ្មានការបង់ថ្លៃសម្រាប់សេវាថែទាំភ្នែក

Senior Whole Health (HMO SNP) គឺជាផែនការសុខភាព Medicare Advantage មួយសម្រាប់ជនជរាអាយុ 65 ឆ្នាំឡើងទៅដែលមាន Medicare និង MassHealth Standard។ សមាជិកទទួលបានអត្ថប្រយោជន៍ Medicare និង MassHealth ទាំងអស់របស់ពួកគេ រួមទាំងការធានារ៉ាប់រងលើឱសថមានវេជ្ជបញ្ជា Part D។ លើសពីនេះ យើងបន្ថែមច្រើនទៀតដូចជា៖

- ប័ណ្ណអ្នកមានសុខភាពល្អ (Healthy You Card) ដើម្បីទិញថ្នាំគ្មានវេជ្ជបញ្ជា និងទំនិញទាក់ទងនឹងសុខភាពមួយចំនួន *(អ្នកទទួលបាន $100 ក្នុងមួយត្រីមាស រហូតដល់ $400 ក្នុងមួយឆ្នាំ)*
- អ្នកផ្តល់ជំនួយតាមផ្ទះជួយអ្នកក្នុងរឿងចំណីអាហារ និងការចល័ត
- ការធ្វើដំណើរទៅមកពីកន្លែងណាត់ជួបពិនិត្យសុខភាព
- សមាជិកម្នាក់ៗទទួលបានអ្នកគ្រប់គ្រងសេវាថែទាំសុខភាពដែលសម្របសម្រួលការមើលថែទាំរបស់អ្នក ដើម្បីឆ្លើយតបនឹងតម្រូវការជាបុគ្គលរបស់អ្នក




គម្រោងមួយ។ ប័ណ្ណមួយ។ Senior Whole Health។

SWH
SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម ហៅទូរស័ព្ទ៖
1-888-566-3526
(TTY 711)
www.seniorwholehealth.com/SNP
ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ 7 ថ្ងៃក្នុងមួយសប្តាហ៍

ប្រសិនបើអ្នកមាន MassHealth Standard តែពុំមានការធានា Medicare ផ្នែក A និង/ឬ ផ្នែក B ទេ អ្នកអាចនឹងមានសិទ្ធិចុះឈ្មោះក្នុងកម្មវិធី MassHealth Senior Care Options (SCO)។

*Senior Whole Health គោរពតាមច្បាប់ស្តីពីសិទ្ធិពលរដ្ឋសហព័ន្ធ ដែលត្រូវអនុវត្ត និងមិនរើសអើងពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត អាយុ ពិការភាព ឬភេទឡើយ។ ATTENTION: If you speak a language other than English, language assistance services, free of charge, are available to you. Call 1-888-794-7268 (TTY 711). ATENCIÓN: si hablas español, tienes a su disposición servicios gratuitos de asistencia lingüística. Llame al 1-888-794-7268 (TTY 711). ATENÇÃO: Se fala português, encontram-se disponíveis serviços linguísticos, grátis. Ligue para 1-888-794-7268 (TTY 711).*

Senior Whole Health (HMO SNP) និង Senior Whole Health NHC (HMO SNP) គឺជាផែនការថែទាំសម្របសម្រួលជាមួយនឹងកិច្ចសន្យាអត្ថប្រយោជន៍ Medicare និងកិច្ចសន្យាជាមួយរដ្ឋម៉ាសាជូសេត/កម្មវិធីសុខភាពសាធារណៈ EOHHS MassHealth។ ការចុះឈ្មោះអាស្រ័យលើការបន្តកិច្ចសន្យាពល់ឆ្នាំ។ ផែនការនេះអាចប្រើបានសម្រាប់អ្នកដែលមានអាយុ 65 ឆ្នាំឡើងទៅដែលទទួលជំនួយវេជ្ជសាស្ត្រពីរដ្ឋនិង Medicare។ H2224_2019_71805





# DIVERSITY
## ADULT DAYCARE CENTER

*"A place where your loved ones can call home"*

**What is Adult Day Care:**
We understand that being a fulltime caregiver is a difficult job. When an elderly loved one needs additional care or supervision during the morning or day, it can create stress for the caregivers of the family. Many families think they have no choice but to quit their jobs or to admit their loved ones into a nursing home or assisted living facility. Diversity Adult Daycare Center (DADC) provides a safe supervised community where elderly adults can socialize, enjoy activities and get assistance with personal care. This will allow the caregivers of the family to have peace of mind when they have an appointment, work obligations or simply to enjoy some personal time.

**Benefits of Adult Day Care for Elderly Adults:**
Attending Adult Day Care has many positive benefits for elderly adults. Your loved ones do not have to be at home feeling lonely with no mental stimulation, when the caretakers are occupied. Being in an Adult Day Care creates a feeling of being in a community, where they can have fun and stay healthy with many activities. Your loved ones will look forward to having their independence and meeting their friends. Having friendships that you see every day promotes feelings of self-worth and camaraderie.

**Services we offer at DADC:**
- Nutritious meals and snacks
- Group fitness classes
- Education classes
- Group field trips and outings
- Fun daily entertainment and activities
- Assistance with personal care
- Salon service
- Transportation
- Monthly birthday parties
- Medical staff
- Gardening

**Who is an ideal candidate for Adult Day Care:**
- 55 years and older
- Southeast Asians & Hispanic
  (we are handicap accessible)

**Forms of payment that we accept:**
- We accept private pay
- All major insurances accepted

433 Elmwood Ave. Providence, R.I 02907
P: 401-427-1337 | F: 401-369-7818
www.diversityadc.com | diversityadc@gmail.com

**Se Habla Español**

We speak English, Spanish, Khmer, Lao, Hmong, Portuguese, Russian and Tagalog.
Come and schedule a free tour of our facility. We will provide free assessment and application assistance.
All major insurances and private pay accepted. Medicaid pays for adult day care, there is no cost to you.

# Boch Honda West

299 Littleton Rd, Westford, MA 01886

**EXIT 32 - OFF 495**

HOME OF THE 20 YEAR 200,000 MILE LIMITED POWERTRAIN ★ WARRANTY ★ BOCH

## ធានាគុណភាព២០ឆ្នាំ ឬ ២០០.០០០ ម៉ាយ
## ដោយគ្មានគិតថ្លៃបន្ថែម

### បើកជុំពិភពលោកហើយ
### នៅតែទទួលការធានាបានទៀត!



ធានាចំពោះតែរថយន្តថ្មីនៅក្នុងស្តុក លើកលែងតែ"ម៉ូដែល"ខ្លះដែលមិន
អាចផ្ទេរបាន - មិនអាចធ្វើបានលើរថយន្តជួលទេ
មានកំរូកិច្ចធានាគុណភាព ដែលអាចមើលបាន នៅហាងលក់រថយន្តរបស់យើង

## 2019 SAVINGS ARE OFFICIALLY HERE!



New 2018 Honda
**CIVIC SPORT**
LEASE FOR
**$99**
PER MONTH FOR 24 MONTHS

New 2018 Honda Civic Sport Manual Hatch with MSRP: $22,540. Lease requires approved credit; based on 12,000 miles per year, $0.15 per mile excess. Lease for $99 per month for 24 months with $4300 due at signing (including $2999 cash or trade down, first month's payment of $99, documentary preparation fee of $495, and bank acquisition of $595). Tax, title, registration, and inspection fees are additional. $0 Security deposit. Lessee is responsible for insurance, maintenance, repairs, excess wear/tear, and $350 disposition fee where permitted by law. Example Stock#: H45855, 180481. Offer ends 2/28/2019.

New 2018 Honda
**ACCORD LX AUTO SEDAN**
LEASE FOR
**$109**
PER MONTH FOR 24 MONTHS

New 2018 Honda Accord Lx Auto Sedan with MSRP: $24,460. Lease requires approved credit; based on 12,000 miles per year, $0.15 per mile excess. Lease for $109 per month for 24 months with $4300 due at signing (including $2999 cash or trade down, first month's payment of $109, documentary preparation fee of $495, and bank acquisition of $595). Tax, title, registration, and inspection fees are additional. $0 Security deposit. Lessee is responsible for insurance, maintenance, repairs, excess wear/tear, and $350 disposition fee where permitted by law. Example Stock#: H44125, H44423, H45526, 180871, 180784, 180410. Offer ends 2/28/2019.

New 2019 Honda
**CR-V LX AWD**
LEASE FOR
**$189**
PER MONTH FOR 24 MONTHS

New 2019 Honda CRV LX AWD UT with MSRP: $26,745. Lease requires approved credit; based on 12,000 miles per year, $0.15 per mile excess. Lease for $189 per month for 24 months with $4300 due at signing (including $2999 cash or trade down, first month's payment of $189, documentary preparation fee of $495, and bank acquisition of $595). Tax, title, registration, and inspection fees are additional. $0 Security deposit. Lessee is responsible for insurance, maintenance, repairs, excess wear/tear, and $350 disposition fee where permitted by law. Example Stock#: H50484, H50686, H50512, 181582. Offer ends 2/28/2019.

New 2019 Honda
**PILOT LX AWD**
LEASE FOR
**$199**
PER MONTH FOR 39 MONTHS

New 2019 Honda Pilot LX AWD UT with MSRP: $34,345. lease requires approved credit; based on 12,000 miles per year, $0.15 per mile excess. Lease for $199 per month for 39 months with $5000 due at signing (including $3500 cash or trade down, first month's payment of $199, documentary preparation fee of $495, and bank acquisition of $595). Tax, title, registration, and inspection fees are additional. $0 Security deposit. Lessee is responsible for insurance, maintenance, repairs, excess wear/tear, and $350 disposition fee where permitted by law. Example Stock#: H50271, H50224, H50695, 190255. Offer ends 2/28/2019.

All advertised prices exclude government fees and taxes, any finance charges, any dealer document processing charges, any electronic filing charges, and any emissions testing charges. See dealer for details. Offers expire 2/28/2019.

**For Vehicle Information**
Contact Nicole Chhun: nchhun@bochhondawest.com

**Salespeople Wanted!**
Contact Kevin Cregg: kcregg@bochhondawest.com

**BochHondaWest.com | (978) 252-2125** HONDA